# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤

លេខៈ ២២៤

ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ២៦៣ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្ធី** ជាប្រធាន

២-លោក ស៊ិន ឌឹម ជាចៅក្រម

៣-លោក ជីវ កេង ជាចៅក្រម

៤-លោក យស់ សូខឿន ជាចៅក្រម

៥-លោក គង់ គីរុន ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក **ម៉ៅ សុធណ្ណ**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ២៧"ច" ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤២៩ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ទេរ៉ូ សេង** (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីនគរបាល ទីលំនៅផ្ទះលេខ ១២៩E₀ ក្រុម២ ផ្លូវជាតិលេខ៥ សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ឪពុកឈ្មោះកែវ ផន"ស"ម្តាយឈ្មោះប៉េ តេះ"រ" ប្រពន្ធឈ្មោះអុនតាន់។

ចុងចម្លើយឈ្មោះ **ឆយ ឌុយ** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូ ទីលំនៅផ្ទះលេខ ១៦៥៤ ក្រុមទី២ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះរស់ ផង់ "ស" ម្តាយឈ្មោះកង អៀ "រ" ប្រពន្ធឈ្មោះទាវ នី ។

មានមេធាវី លោក ម៉ន កែវស៊ីន ។

<u>**ចម្បងខ្លួនរឿង**</u> : ប្តឹងសុំឱ្យគោរពកិច្ចសន្យា .

បានឃើញបណ្តឹងសាទុក្ខលេខ១០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះគយ ធុល និងឈ្មោះទាវ នី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២៧"ច" ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៤ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៤-១១-២០០២ របស់ឈ្មោះខៀវ សេង ហៅ កែវ ប៉ូ ប្តឹងឱ្យឈ្មោះគយ ធុល និងប្រពន្ធឈ្មោះទាវ នី គោរពកិច្ចសន្យា ដោយហេតុថា :កាលពីថ្ងៃទី២៥-៣-២០០២ ឈ្មោះគយ ធុល និងប្រពន្ធឈ្មោះទាវនី បានព្រមព្រៀងគ្នាលក់ផ្ទះមួយកន្លែងស្ថិតនៅក្នុងក្រុមទី២ ភូមិសាមគ្គី ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឱ្យមកខ្លួនក្នុងតំលៃ ២.០០០ដុល្លាអាមេរិក ដោយបានធ្វើកិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី២៥-០៣-២០០២ ត្រឹមត្រូវតាមផ្លូវច្បាប់ ។ ពេលព្រមព្រៀងប្រគល់ផ្ទះលេខ ១៦៥៤ រួចមក ពីរនាក់ប្តីប្រពន្ធបានប្រាប់ខ្លួនថាខ្លួនរកទិញផ្ទះពុំទាន់បាន សុំជួលផ្ទះដែលលក់ឱ្យខ្លួនរួចហើយ នេះមកស្នាក់នៅបណ្តោះអាសន្នរយៈពេល៩ខែ សិន ដោយឱ្យឈ្នួលក្នុង០១ខែ តំលៃ ១០០ដុល្លា និងបានធ្វើកិច្ចសន្យាជួលផ្ទះចុះថ្ងៃទី២៥-៣-២០០២ ក្រោយពេលជួលឈ្មោះគយ ធុល និងប្រពន្ធឈ្មោះទាវ នី មិនបានបង់ថ្លៃឈ្នួលផ្ទះ និង ពុំព្រមចេញពីផ្ទះតាមកិច្ចសន្យាដែលបានធ្វើជាមួយខ្លួននោះទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១១"ខ" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះខៀវ សេង ហៅ កែវ ប៉ូ ភេទប្រុស អាយុ៣៨ឆ្នាំ ចុះថ្ងៃទី១៤-១១-២០០២ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះគយ ធុល ភេទប្រុស អាយុ៨៦ឆ្នាំ ប្រគល់ដី និងផ្ទះលេខ ១៦៥៤ ដែលមានទំហំ ៩ម x ៧ម ស្ថិតនៅក្នុងក្រុមទី២ ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ព្រមទាំងប្រាក់ឈ្នួលគិតក្នុង១ខែ ១០០ដុល្លារអាមេរិក តាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យាចុះថ្ងៃទី២៥-៣-២០០២ និង បង់ប្រាក់ឈ្នួលនេះ គិតពីថ្ងៃទី២៧-៣-២០០២ ដល់ថ្ងៃទី២៧-៣-២០០៣ សរុបទាំងអស់ចំនួន ១២០០ដុល្លាអាមេរិក បញ្ចុះឱ្យនៅត្រឹម ១.០០០ដុល្លាអាមេរិក ទូទាត់ឱ្យដើមចោទ ។ សំណូមពរដើមចោទទាមទារប្រាក់ឈ្នួលលើសពីនេះ បដិសេធចោល ។ ទុកពេលវេលាចំនួន៦០ថ្ងៃ សំរាប់ឱ្យចុងចម្លើយអនុវត្តនូវសេចក្តីសំរេចនៃសាលក្រមនេះ ដោយចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ក្នុងករណីរឹងរូសមិនព្រមអនុវត្ត សំរេចដាក់គុកតាមច្បាប់ ។

៣-បង្គាប់អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន

១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និងរង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០៛ សរុប ៧.០០០៛ ។ កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១ភាគរយ នៃប្រាក់ចំនួន ៣.០០០ដុល្លារអាមេរិក ។ ប្រាក់ពន្ធសមាមាត្រសំរាប់បង់ចូលថវិការដ្ឋ ៨០ភាគរយ និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ហើយឱ្យដើមចោទបង់ទុកជាមុនសិន ទើបបង្គាប់អោយចុងចម្លើយបង់ប្រាក់នេះ សងទៅដើមចោទវិញជាក្រោយ ។

៤-សាលក្រមនេះជំនុំជំរះ ចំពោះមុខដើមចោទ និងចុងចម្លើយ នៅថ្ងៃទី២៨-២-២០០៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី៤-៣-២០០៣ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រមស្ថាប័នមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ព្រមទាំងកងកំលាំងប្រដាប់អាវុធគ្រប់តំណែងអោយជួយអនុវត្តសាលក្រមនេះ ឱ្យបានសំរេច កាលបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៥"ឧ"ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះទាវ នី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១១"ឧ"ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៧"ច" ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-មិនទទួលជំនុំជំរះ លើពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-៥-២០០៣ របស់ឈ្មោះទាវ នី ដោយបណ្តឹងឧទ្ធរណ៍នេះ ធ្វើឡើងហួសកាលកំណត់នៃច្បាប់ ។

២-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះគយ ធុល បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥.០០០៛ និងលើអាជ្ញាធរតុលាការចំនួន ៥.០០០៛ ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ និងមេធាវីការពារចុងចម្លើយ កំបាំងមុខដើមចោទ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះគយធុល និងឈ្មោះទាវ នី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២៧"ច" ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះគយ ធុល និងឈ្មោះទាវ នី ។

បានឃើញសារណាតបចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះខៀវ សេង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : បណ្តឹងឧទ្ធរណ៍ហួសកំណត់ច្បាប់ សូមក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះទាវ នី នាពេលសវនាការថា : ពីមុនខ្លួនខ្ចីលុយគាត់ គាត់បានបោកប្រាស់យកផ្ទះខ្លួន ខ្លួនធ្វើកិច្ចសន្យាបញ្ចាំ មិនមែនធ្វើកិច្ចសន្យាលក់ផ្ទះទេ ។ ខ្លួនល្ងង់មិនដឹងពីការប្តឹងឧទ្ធរណ៍ទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះខៀវ សេង នាពេលសវនាការថា : ផ្ទះនេះសព្វថ្ងៃ ខ្លួនជាអ្នកកាន់កាប់ គាត់ផ្ទេរសិទ្ធិឱ្យខ្លួនគិតជាតំលៃ ២.០០០ដុល្លាអាមេរិក ហើយរដ្ឋអំណាចក៏បានដឹងឮដែរ ។ ការប្រគល់លុយ គឺខ្លួនប្រគល់ឱ្យគ្រប់ ២.០០០ដុល្លាអាមេរិក តែម្តង ។ ផ្ទះនេះសព្វថ្ងៃខ្លួនជួលឱ្យកម្មករកាត់ដេរបាន៤បន្ទប់ ជាមធ្យមក្នុង១ខែ ជួលបាន ៥០ដុល្លាអាមេរិក ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៤ របស់គយ ធុល និងប្រពន្ធ ទាវ នី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា ការដែលចុងចម្លើយលើកឡើងនៅពេលសវនាការនេះ ក៏ដូចជាក្នុងសារណាដែរ ដែលថា ផ្ទះទំនាស់នេះ គឺជាផ្ទះដាក់បញ្ចាំធានាបំណុល ពុំមែនលក់ទេនោះ តុលាការកំពូលពេលនេះពុំអាចពិចារណាបានទេ ពីព្រោះបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយផុតកំណត់ច្បាប់ឱ្យប្តឹងឧទ្ធរណ៍តាមមាត្រា៧ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា សាលដីកាលេខ ២៧"ច" ចុះថ្ងៃទី១៨-៣-២០០៤ របស់សាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## សំរេចយកសេចក្តីចំពោះមុខគូភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ១០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះគយធុល និង ទាវ នី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ២៧"ច"ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដែលឈ្មោះ គយ ធុល បានបង់នៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០រៀល

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ។